ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ



# បណ្ណាល័យ
# សម្ដេចព្រះសង្ឃរាជ ជួន ណាត

## ផែនការយុទ្ធសាស្ត្រ
## ២០២៤ - ២០២៨

ខែមករា ឆ្នាំ២០២៤

## បុព្វកថា

ការសិក្សាពេញមួយជីវិត គឺជាគោលការណ៍នៃការអប់រំនៅសតវត្សរ៍ទី២១ ដែលមានគោលបំណង អភិវឌ្ឍមូលធនមនុស្ស ឱ្យក្លាយជាធនធានមានសមត្ថភាពពេញលេញ ដើម្បីធ្វើកំណែទម្រង់ និងការឆ្លើយតប។ ការអភិវឌ្ឍបណ្ណាល័យឱ្យក្លាយទៅជាបណ្ណាល័យស្តង់ដា និងជាមជ្ឈមណ្ឌលធនធានចំណេះដឹងដ៏សំខាន់សម្រាប់ សិស្សានុសិស្ស និស្សិត អ្នកសិក្សា គ្រូបង្រៀន អ្នកស្រាវជ្រាវ និងអ្នកអានទូទៅ គឺជាការរួមចំណែកធ្វើឱ្យសម្រេច គោលការណ៍សិក្សាពេញមួយជីវិត ដែលទាមទារឱ្យអ្នកសិក្សាចេះរៀនដោយខ្លួនឯងតាមមធ្យោបាយផ្សេងៗ និង គ្រប់ទីកន្លែងហើយមានសមត្ថភាពបំពេញការងារក្នុងយុគសម័យឌីជីថល។

ក្រសួងអប់រំ យុវជន និងកីឡា បាននឹងកំពុងធ្វើការសម្រួចអាទិភាពនៃកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ដោយដាក់ចេញនូវអាទិភាពស្នូលចំនួនប្រាំបី សម្រាប់ឆ្នាំ២០២៤-២០២៨ ក្នុងការអនុវត្តផែនការ យុទ្ធសាស្ត្រវិស័យអប់រំប្រកបដោយប្រសិទ្ធភាព តាំងពីថ្នាក់ជាតិរហូតដល់សាលារៀន។ ការធ្វើបរិវត្តកម្មបណ្ណាល័យ ចេញពីបណ្ណាល័យបែបប្រពៃណីឱ្យក្លាយទៅជាបណ្ណាល័យស្វ័យប្រវត្តិ និងបណ្ណាល័យអេឡិចត្រូនិក(E-Library) គឺដើម្បីធ្វើឱ្យសម្រេចផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងគោលដៅនៃការអភិវឌ្ឍមូលធនមនុស្សសតវត្សរ៍ទី២១។

ឯកសារ «ផែនការយុទ្ធសាស្ត្របណ្ណាល័យ» សម្រាប់ឆ្នាំ២០២៤-២០២៨ ត្រូវបានរៀបចំឡើង ដើម្បី ពង្រឹង និងលើកកម្ពស់គុណតម្លៃវិទ្យាស្ថានជាតិអប់រំឱ្យទៅជាមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូ ប្រកបដោយឧត្តមភាព និងជាគ្រឹះស្ថានឧត្តមសិក្សាពេញលេញប្រកបដោយគុណភាព។ ផែនការយុទ្ធសាស្ត្រនេះ មានផ្នែកសំខាន់ៗ ដូចជាស្ថានភាពបច្ចុប្បន្ន ផែនការយុទ្ធសាស្ត្រ វិស័យយុទ្ធសាស្ត្រ គោលដៅ ក្របខណ្ឌពិនិត្យតាមដាន និង ផែនការសកម្មភាព។ល។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមយ៉ាងមុតមាំថា ឯកសារ «ផែនការយុទ្ធសាស្ត្របណ្ណាល័យ» សម្រាប់ ឆ្នាំ២០២៤-២០២៨នេះ នឹងក្លាយជាឧបករណ៍ដ៏មានតម្លៃ សម្រាប់ជួយពង្រឹងវិទ្យាស្ថានជាតិអប់រំ ឱ្យជានាបាន នូវការផ្តល់ចំណេះដឹងជំនាញឯកទេស គរុកោសល្យ បំណិនស្រាវជ្រាវ និងនវានុវត្តន៍ ប្រកបដោយ បរិយាបន្ន ក្នុងការអភិវឌ្ឍមូលធនមនុស្សកម្ពុជា។

ថ្ងៃចន្ទ ៤រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# អារម្ភកថា

បណ្ណាល័យ **សម្តេចព្រះសង្ឃរាជ ជួន ណាត** មានចក្ខុវិស័យប្រែក្លាយជាបណ្ណាល័យឌីជីថលសតវត្សរ៍ទី២១ ដែលមានឧត្តមភាពឈានមុខគេ លើការផ្តល់ធនធានសិក្សាដល់ភាគីពាក់ព័ន្ធនានា ក្នុងសហគមន៍អ្នកអប់រំ និងគ្រូបង្រៀន។ ផ្តើមចេញពីការពង្រីកខ្លួនឯងឱ្យស្របទៅនឹងចក្ខុវិស័យនៃឧត្តមភាពរបស់ខ្លួន បណ្ណាល័យត្រូវការបង្កើតផែនការយុទ្ធសាស្ត្រសម្រាប់រយៈពេល៥ឆ្នាំខាងមុខ។

ក្នុងដំណើរការចងក្រងសៀវភៅផែនការយុទ្ធសាស្ត្រ៥ឆ្នាំ របស់បណ្ណាល័យសម្តេចព្រះសង្ឃរាជ ជួន ណាត វិទ្យាស្ថានជាតិអប់រំបានសហការជាមួយអង្គការវីអេសអូកម្ពុជាក្នុងសកម្មភាពជាច្រើន ដើម្បីវិភាគលើស្ថានភាពបណ្ណាល័យបច្ចុប្បន្ន និងបានប្រមូលយកអនុសាសន៍ មតិ ទស្សនៈនានាពីថ្នាក់ដឹកនាំវជអ អ្នកជំនាញជាតិ និងអន្តរជាតិ និងបណ្ណារក្ស។ បន្ថែមពីនេះ ក្រុមការងារអ្នកនិពន្ធបានសិក្សាស្រាវជ្រាវស៊ីជម្រៅ លើប្រធានបទបណ្ណាល័យ តាមរយៈកិច្ចពិភាក្សាក្រុម ការសម្ភាសន៍ផ្ទាល់ និងតាមអនឡាញ។ ជាពិសេស ការធ្វើទស្សនកិច្ចសិក្សាទៅកាន់បណ្ណាល័យផ្សេងៗទៀតដើម្បីប្រមូលជាធាតុចូលបន្ថែមក្នុងឯកសារនេះ។ ជាលទ្ធផលផែនការយុទ្ធសាស្ត្រនេះបានសម្រេចជាឯកសារគោលសម្រាប់ផ្តល់ការណែនាំ និងទិសដៅលម្អិតនានាផ្តើមចេញពីការវិភាគSWOT ទៅលើស្ថានភាពជាក់ស្តែងនៃបណ្ណាល័យបច្ចុប្បន្ន ការដាក់ចេញនូវគោលដៅ ផែនការសកម្មភាព និងក្របខណ្ឌពិនិត្យតាមដានក្នុងការវាយតម្លៃវឌ្ឍនភាពបណ្ណាល័យសម្រាប់រយៈពេល៥ឆ្នាំខាងមុខយ៉ាងច្បាស់លាស់។

យើងខ្ញុំទាំងអស់គ្នាជាក្រុមអ្នកនិពន្ធសង្ឃឹមថា ឯកសារផែនការយុទ្ធសាស្ត្រ៥ឆ្នាំបណ្ណាល័យនេះ នឹងក្លាយជាត្រីវិស័យនាំផ្លូវសម្រាប់ការដឹកនាំ ការផ្លាស់ប្តូរជាវិជ្ជមាន ប្រកបដោយគុណតម្លៃ និងឧត្តមភាពក្នុងការសម្រេចចក្ខុវិស័យបណ្ណាល័យឌីជីថលសតវត្សទី២១នាពេលអនាគត។

**គណៈកម្មការនិពន្ធ**

ចងក្រង និងបោះពុម្ពដោយ៖ វិទ្យាស្ថានជាតិអប់រំ ខែធ្នូ ឆ្នាំ២០២៣
គាំទ្រថវិកាដោយ៖ គម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ (USESDP-II)
គាំទ្របច្ចេកទេសដោយ៖ អង្គការវីអេសអូ កម្ពុជា
© វិទ្យាស្ថានជាតិអប់រំ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០២៣

## គណៈកម្មការនិពន្ធ

| | |
|---|---|
| ១-លោកបណ្ឌិត **Neil Rose** | ទីប្រឹក្សាគ្រប់គ្រងអប់រំនៃអង្គការVSO |
| ២-លោក **ជិន សំអឿន** | ប្រធានគម្រោងនៃអង្គការVSO |
| ៣-លោក **ហ៊ន សុវណ្ណារិទ្ធិ** | មន្ត្រីសម្របសម្រួលគម្រោងនៃអង្គការVSO |
| ៤-លោក **នេត វណ្ណា** | ប្រធានបណ្ណាល័យ **ហ៊ុន សែន** |
| ៥-លោក **ម៉ុក វ៉ាស៊ី** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |

## គណៈកម្មការគ្រប់គ្រង

| | |
|---|---|
| ១-ឯ.ឧ.បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា |
| ២-ឯ.ឧ.បណ្ឌិតសភាចារ្យ **ណាត ប៊ុន រឿន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ៣-ឯ.ឧ.បណ្ឌិត **ឌី ខាំបូលី** | ប្រធានគណៈកម្មាធិការកំណែទម្រង់នៃវជអ |
| ៤-លោកជំទាវបណ្ឌិត **ឃួន វិច្ឆិកា** | អគ្គនាយករងអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| ៥-ឯ.ឧ.បណ្ឌិត **សៀង សុវណ្ណា** | នាយកវិទ្យាស្ថានជាតិអប់រំ |
| ៦-លោក **ថៃ ហេង** | នាយករងវិទ្យាស្ថានជាតិអប់រំ |

## គណៈកម្មការត្រួតពិនិត្យ និងកែលម្អ

| | |
|---|---|
| ១-លោក **យិន ធី** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| ២-លោក **លាង តុលា** | ប្រធានបណ្ណាល័យសម្តេចព្រះសង្ឃរាជ ជួន ណាត |
| ៣-លោក **ប្រាជ្ញ ច័ន្ទសុខា** | អនុប្រធានបណ្ណាល័យសម្តេចព្រះសង្ឃរាជ ជួន ណាត |
| ៤-លោកស្រី **ប៊ូ សុខច័ន្ទ** | អនុប្រធានបណ្ណាល័យសម្តេចព្រះសង្ឃរាជ ជួន ណាត |
| ៥-លោកស្រី **រ៉ូច ណៃ** | បណ្ណារក្សនៃបណ្ណាល័យសម្តេចព្រះសង្ឃរាជ ជួន ណាត |
| ៦-លោក **បាន កក្កដា** | បណ្ណារក្សនៃបណ្ណាល័យសម្តេចព្រះសង្ឃរាជ ជួន ណាត |
| ៧-លោក **ហាំ ចាន់ណា** | បណ្ណារក្សនៃបណ្ណាល័យសម្តេចព្រះសង្ឃរាជ ជួន ណាត |
| ៨-លោកស្រី **សេង សច្ចា** | គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ |
| ៩-លោក **ញែម ចន្ទា** | គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ |
| ១០-លោក **ជីវ ពេជ្រចិន្តា** | គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ |

| | |
|---|---|
| ១១-លោក **ម៉ុក វ៉ាស៊ី** | ប្រធានការិ.នា.អភិវឌ្ឍកម្មវិធីសិក្សា |
| ១២-លោក **ហ៊ុន ឡាវ** | មន្ត្រីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| ១៣-លោក **ព ធូយ** | មន្ត្រីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| ១៤-លោកស្រី **ណាត ស៊ីវឡាយ** | អនុប្រធានការិ.នា.មធ្យមសិក្សាចំណេះទូទៅ |
| ១៥-លោកស្រី **តេង សុភាលក្សី** | អនុប្រធានការិ.នា.មធ្យមសិក្សាចំណេះទូទៅ |
| ១៦-លោកស្រី **ប៉ាក បូរ៉ានី** | អនុប្រធានការិ.នា.មធ្យមសិក្សាចំណេះទូទៅ |
| ១៧-លោក **អ៊ុច ផលរដ្ឋ** | គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ |
| ១៨-លោក **ហេង វិបុល** | គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ |
| ១៩-លោកស្រី **ឡាយ នារី** | គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ |
| ២០-លោក **នៅ វុត្ថា** | គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ |
| ២១-លោក **ឆេង សារុន** | គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ |

២២-ក្រុមការងារនៃអង្គការVSO

២៣-អង្គការ KAPE

# មាតិកា


បញ្ជីអក្សរកាត់ ...... ៦

សេចក្តីផ្តើម ...... ៧

សារតាររបស់បណ្ណាល័យវិទ្យាស្ថានជាតិអប់រំ ...... ៧

ដំណើរការអភិវឌ្ឍផែនការយុទ្ធសាស្ត្របណ្ណាល័យ ...... ៨

ស្ថានភាពបច្ចុប្បន្ន ...... ៨

ផែនការយុទ្ធសាស្ត្របណ្ណាល័យសម្តេចព្រះសង្ឃរាជ ជួន ណាត (២០២៤ - ២០២៨) ...... ១០

វិស័យយុទ្ធសាស្ត្រ ...... ១២

- គោលដៅទី ១៖ កម្មវិធី ការណែនាំ និងការផ្សព្វផ្សាយ ...... ១៣
- គោលដៅទី២៖ ការពង្រឹងសមត្ថភាពបណ្ណាល័យ ...... ១៤
- គោលដៅទី៣ ៖ ភាពជាដៃគូ និងបណ្តាញ ...... ១៥

ក្របខណ្ឌពិនិត្យតាមដាន ...... ១៥

ផែនការសកម្មភាពបណ្ណាល័យសម្តេចព្រះសង្ឃរាជ ជួន ណាត ២០២៤-២០២៨ ...... ៣២

ឧបសម្ព័ន្ធ១៖ បណ្ណាល័យសម្តេចសង្ឃរាជ ជួន ណាត ៖ គំរូប្លង់សាងសង់ ...... ៤២

## បញ្ជីអក្សរកាត់

| | |
|---|---|
| វជអ | វិទ្យាស្ថានជាតិអប់រំ |
| អយក | ក្រសួងអប់រំ យុវជន និងកីឡា |
| KAPE | អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា |
| JICA | Japan International Cooperation Agency |
| VLE | Visual Learning Environment |
| VSO | Voluntary Service Overseas |

## សេចក្តីផ្តើម

វិទ្យាស្ថានជាតិអប់រំមានចក្ខុវិស័យដ៏មុតមាំ ដោយចង់ប្រែក្លាយខ្លួនជាមជ្ឈមណ្ឌលឧត្តមភាពមួយលើការអប់រំគ្រូបង្រៀន ការអភិវឌ្ឍវិជ្ជាជីវៈ និងការសិក្សាស្រាវជ្រាវ។ មជ្ឈមណ្ឌលឧត្តមភាពនេះនឹងត្រូវកែប្រែទៅជាគ្រឹះស្ថានឧត្តមសិក្សាពេញលេញមួយដែលមានតួនាទីសំខាន់បីរួមមាន (១) ជាគ្រឹះស្ថានឧត្តមសិក្សាពេញលេញដែលផ្តល់កម្មវិធីកម្រិតសញ្ញាបត្រ (២) ជាគ្រឹះស្ថានបណ្តុះបណ្តាលដំបូង និងការបណ្តុះបណ្តាលបន្តដល់គ្រូបង្រៀន និងមន្រ្តីគ្រប់គ្រងអប់រំគ្រប់កម្រិត (៣) ជាមជ្ឈមណ្ឌលស្រាវជ្រាវអប់រំដែលផ្តល់អនុសាសន៍ផ្អែកលើភស្តុតាងដើម្បីផ្សព្វផ្សាយគោលនយោបាយក្រសួងអប់រំ យុវជន និងកីឡា និងទិសដៅយុទ្ធសាស្ត្ររបស់វិទ្យាស្ថានជាតិអប់រំ។ អាស្រ័យហេតុនេះទើបវិទ្យាស្ថានជាតិអប់រំត្រូវមានបេសកកម្មរបស់ខ្លួនក្នុងការលើកកម្ពស់ការបង្រៀន និងការរៀនសតវត្សទី២១ និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់គ្រូបង្រៀន អ្នកដឹកនាំអប់រំ និងអ្នកស្រាវជ្រាវកម្ពុជា។

ដើម្បីអាចសម្រេចគោលដៅប្រកបដោយចក្ខុវិស័យបែបនេះ បណ្ណាល័យសម្តេចព្រះសង្ឃរាជ **ជួន ណាត** ត្រូវតែពង្រីកខ្លួនឯងឱ្យសមស្របទៅនឹងចក្ខុវិស័យនៃឧត្តមភាពរបស់ខ្លួន ដោយការបង្កើតផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ។ ផែនការយុទ្ធសាស្ត្រ៥ឆ្នាំនេះនឹងមិនត្រឹមតែជួយឱ្យវិទ្យាស្ថានជាតិអប់រំធានាបាននូវគុណភាពលើការផ្តល់ចំណេះដឹងជំនាញឯកទេស និងគរុកោសល្យបង្រៀនប៉ុណ្ណោះទេ តែថែមទាំងផ្តល់បំណិនស្រាវជ្រាវ និងបរិយាបន្នដែលមានបច្ចុប្បន្នភាពដល់អ្នកដឹកនាំផ្នែកអប់រំ គ្រូឧទ្ទេស គ្រូបង្រៀន អ្នកស្រាវជ្រាវ និស្សិត និងអ្នកសិក្សាកម្ពុជា។ កត្តាលើកកម្ពស់ទាំងអស់នេះនឹងចូលរួមចំណែកដល់ការអភិវឌ្ឍអនាគតយុវជនកម្ពុជា ឱ្យក្លាយខ្លួនជាកម្លាំងពលកម្មជំនាញនាសតវត្សទី២១ ប្រកបដោយគំនិតច្នៃប្រឌិត ភាពឈ្លាសវៃ សមត្ថភាព និងវិបុលភាព ដោយធានាថាប្រទេសកម្ពុជាមានការប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្មនៅលើឆាកអន្តរជាតិប្រកបដោយសក្តានុពល។

## សាវតាររបស់បណ្ណាល័យវិទ្យាស្ថានជាតិអប់រំ

បណ្ណាល័យនៃវិទ្យាស្ថានជាតិអប់រំបានបង្កើតឡើងដំបូងនៅឆ្នាំ១៩៩៥ ដោយមានធម្មជាតិជាបណ្ណាល័យឯកទេសខាងគរុកោសល្យ គ្រប់គ្រងដោយលោក **នាង មុត** និងទទួលបានការឧបត្ថម្ភដោយអង្គការ CCCL (Centre de Coopération Culturelle Linguistique ក្រោយមកក្លាយជាវិទ្យាស្ថានវប្បធម៌បារាំង) ព្រមទាំងអង្គការ JICA ដែលបានផ្គត់ផ្គង់ឱ្យមានបន្ទប់មួយទំហំ ១៥.៥០ម X ៩.២០ម ហៅថា "**បណ្ណាល័យ** JICA"។ ក្រោយមកទៀត វិទ្យាស្ថានជាតិអប់រំបានបង្កើតបណ្ណាល័យមួយផ្សេងទៀតដែលមានឈ្មោះថា NETREC (The National English Teaching Resource Center = មជ្ឈមណ្ឌលធនធានជាតិនៃការបង្រៀនភាសាអង់គ្លេស) នៅអំឡុងឆ្នាំ ១៩៩៨ ក្រោមជំនួយរបស់ British Council អង្គការ និងបណ្តាស្ថានទូតនានាប្រចាំនៅប្រទេសកម្ពុជា។ លុះដល់ឆ្នាំ២០០៤ ក្រោមការដឹកនាំរបស់លោកនាយក **អ៊ឹម ភុច** បណ្ណាល័យNETREC ក៏ត្រូវបានរំសាយចោលដោយប្រមូលបញ្ចូលនូវរាល់ឯកសារនានាមកក្នុងបណ្ណាល័យ JICA ព្រមទាំងបានផ្លាស់ប្តូរឈ្មោះបណ្ណាល័យថ្មីនេះមកជា "**បណ្ណាល័យវិទ្យាស្ថានជាតិអប់រំ**" ។ ឆ្លងតាមការវិវត្តដ៏សម្បូរបែបនេះ បណ្ណារក្សគ្រប់រូបបានខិតខំប្រឹងប្រែងអភិវឌ្ឍសមត្ថភាពរបស់ខ្លួនលើជំនាញគ្រប់គ្រងបណ្ណាល័យ និងមានឆន្ទៈមនសិការវិជ្ជាជីវៈ ដែលជាហេតុនាំឱ្យបណ្ណាល័យមានការផ្លាស់ប្តូរជាវិជ្ជមាន។ នៅឆ្នាំ២០២៤ បណ្ណាល័យ

"**សម្តេចព្រះសង្ឃរាជ ជួន ណាត**" និងបើកទ្វារទទួលអ្នកសិក្សានៅក្នុងវិទ្យាស្ថានជាតិអប់រំដោយមានធនធានសម្បូរបែប សាកសមជាបណ្ណាល័យឌីជីថលនាសតវត្សទី២១។ សូមមើលឧបសម្ព័ន្ធទី១ សម្រាប់ឧទាហរណ៍នៃការរចនាថ្មី។

## ដំណើរការអភិវឌ្ឍផែនការយុទ្ធសាស្ត្របណ្ណាល័យ

នៅក្នុងដំណើរការអភិវឌ្ឍផែនការយុទ្ធសាស្ត្រ៥ឆ្នាំរបស់បណ្ណាល័យនៃវិទ្យាស្ថានជាតិអប់រំ ត្រូវមានការឆ្លងកាត់ការពិភាក្សាយ៉ាងទូលំទូលាយជាមួយអ្នកពាក់ព័ន្ធសំខាន់ៗជាច្រើននាក់ ក្នុងការស្រាវជ្រាវវិភាគលើឯកសារដែលមានស្រាប់។ អ្នកដែលបានចូលរួមផ្តល់ជាតុចូលលើឯកសារនេះមានចំណែកពាក់ព័ន្ធក្នុងសហគមន៍បណ្ណាល័យជាតិ និងអន្តរជាតិ រួមមានអ្នកជំនាញផ្នែកបណ្ណាល័យ បណ្ណារក្សវិទ្យាស្ថានជាតិអប់រំ មន្ត្រីជំនាញមកពីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នាយកសាលា គ្រូបង្រៀន និងអ្នកសិក្សាជាច្រើននាក់ទៀត។

មតិយោបល់របស់អ្នកពាក់ព័ន្ធត្រូវបានប្រមូលយកមកធ្វើជាសំណុំទិន្នន័យបែបគុណវិស័យ និងវិភាគសំយោគទៅតាមប្លង់ ដោយមានការប្រើប្រាស់កម្មវិធី Excel ជាជំនួយ។ ទិន្នន័យទាំងនេះត្រូវបានសំយោគ ដើម្បីបង្កើតបានជាគំនិតរួមជាអនុសាសន៍ និងសកម្មភាពអនុវត្តផ្សេងៗ។ ការវិភាគ SWOT ត្រូវបានយកមកអនុវត្តដើម្បីវិភាគពិចារណាវែកញែកនូវជាតុចូល និងការរួមចំណែករបស់អ្នកពាក់ព័ន្ធទាំងអស់។ ជាលទ្ធផល ការវិភាគនេះត្រូវបានបង្ហាញស្របតាមស្ថានភាពបច្ចុប្បន្ន និងផ្តល់ជាគោលដៅបីសំខាន់ៗសម្រាប់ផែនការយុទ្ធសាស្ត្រ៥ឆ្នាំរបស់វិទ្យាស្ថានជាតិអប់រំ ដូចខាងក្រោមនេះ៖

## ស្ថានភាពបច្ចុប្បន្ន

| ការវិភាគ SWOT | |
|---|---|
| **ភាពខ្លាំង** | **ភាពខ្សោយ** |
| • មានបណ្ណារក្សគ្រប់គ្រាន់ ដើម្បីគាំទ្រមុខងារបណ្ណាល័យបច្ចុប្បន្ន<br>• អ្នកគ្រប់គ្រងបណ្ណាល័យមានឥរិយាបថចង់ឱ្យមានការផ្លាស់ប្តូរជាវិជ្ជមានចំពោះបណ្ណាល័យ។ | • គ្មានគណៈកម្មការបណ្ណាល័យ។<br>• ហេដ្ឋារចនាសម្ព័ន្ធរូបវន្តបច្ចុប្បន្នមិនទាន់ឆ្លើយតបចក្ខុវិស័យបណ្ណាល័យសតវត្សទី ២១នៅឡើយ ឯកសារ និងធនធានរូបវន្តក្នុងបណ្ណាល័យមួយចំនួនមានភាពចំណាស់ និងហួសសម័យកាល។<br>• គ្មានរចនាសម្ព័ន្ធគ្រប់គ្រងបណ្ណាល័យ (ឧទាហរណ៍៖គ្មានតារាងពេលវេលាសម្រាប់កិច្ចប្រជុំ និងផែនការសកម្មភាព។ល។)<br>• ការទំនាក់ទំនងរវាងបណ្ណាល័យ និងអ្នកប្រើប្រាស់សេវាកម្មបណ្ណាល័យនៅមានកម្រិត។<br>• ការផ្សារភ្ជាប់គ្នានៅមានកម្រិតលើការគាំទ្រដល់ការសិក្សាក្នុងថ្នាក់រៀនរបស់អ្នកសិក្សា ឬសហគមន៍គ្រូបង្រៀនដែលធំជាងនេះ។ |

| | |
|---|---|
| | • ឯកសារបច្ចុប្បន្នមិនបានធ្វើកាតាឡុកពេញលេញនៅឡើយ។<br>• ការធ្វើកាតាឡុកមានភាពយឺតយ៉ាវខ្លាំង។ មានសៀវភៅត្រឹមតែ១៥៧៧ក្បាល ក្នុងចំណោម ១០០០០ក្បាលបានធ្វើកាតាឡុករួចរាល់គិតត្រឹមខែកក្កដា ឆ្នាំ២០២៣។<br>• ចំណេះដឹងភាសាអង់គ្លេសរបស់បណ្ណារក្សភាគច្រើននៅមានកម្រិតដែលជាហេតុនាំឱ្យការធ្វើកាតាឡុកមិនទាន់បានល្អ។<br>• ឯកសារមានសភាពហួសសម័យ ដោយសារឯកសារភាគច្រើនជាឯកសារអំណោយពីបណ្ណាល័យបរទេស។<br>• មិនទាន់មានកញ្ចប់ថវិកាបណ្ណាល័យជាក់លាក់សម្រាប់ដំណើរការបណ្ណាល័យនៅឡើយ។<br>• ធនធានឯកសារនៅលើអ៊ីនធឺណិតនៅមានកម្រិត។<br>• បណ្ណារក្សមកធ្វើការមិនទៀងទាត់បណ្តាលឱ្យបណ្ណាល័យមិនអាចបើកទ្វារទទួលអ្នកសិក្សាពេញលេញតាមម៉ោងកំណត់។<br>• បណ្ណារក្សទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈជាប្រចាំលើកម្មវិធី KOHA តែប៉ុណ្ណោះនាពេល ៥ខែកន្លងមកនេះ។<br>• សកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅមានកម្រិតខ្លាំង។<br>• គ្មានផែនការណែនាំតម្រង់ទិសដល់បណ្ណារក្សចូលថ្មី។<br>• បណ្ណាល័យមិនទាន់បានផ្តល់ការគាំទ្រដល់មុខវិជ្ជាឯកទេស – កូនសៀវភៅ/ព័ត៌មានតាមអ៊ីនធឺណិត។<br>• មិនទាន់មានកម្មវិធីតម្រង់ទិសណែនាំអំពីរបៀបប្រើប្រាស់បណ្ណាល័យសម្រាប់អ្នកសិក្សាថ្មី និងសមាជិកមហាវិទ្យាល័យនៅឡើយទេ។<br>• បុគ្គលិក និងអ្នកសិក្សាកម្រមកមើល ឬប្រើប្រាស់បណ្ណាល័យណាស់។ |

| ឱកាស | ឧបសគ្គ |
|---|---|
| • មានគម្រោងក្នុងការសាងសង់បណ្ណាល័យថ្មី ដើម្បីពង្រីកខ្លួនឱ្យទៅជាមជ្ឈមណ្ឌលធនធានសិក្សាទំនើប (RLC)។<br>• មានលទ្ធភាពអាចអភិវឌ្ឍខ្លួនដើម្បីគាំទ្រចក្ខុវិស័យថ្មីរបស់វជអក្នុងការប្រែក្លាយជាមជ្ឈមណ្ឌលឧត្តមភាព និងមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវ។<br>• មានសក្តានុពលដ៏ធំសម្រាប់ការវិវត្តជាវិជ្ជមាន។<br>• មានការផ្សារភ្ជាប់ខ្លួនទៅកាន់សហគមន៍អប់រំកាន់តែទូលំទូលាយ។<br>• មានបណ្ណារក្សពីរនាក់កំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើការគ្រប់គ្រងបណ្ណាល័យ ដែលជំរុញដល់ការចែករំលែកចំណេះដឹង និងការអភិវឌ្ឍសមត្ថភាពរបស់បណ្ណារក្ស។<br>• មានឯកសារចងក្រងស្របតាមស្តង់ដានវានុវត្តន៍អន្តរជាតិ ដោយការធ្វើចំណាត់ថ្នាក់តាមប្រព័ន្ធ Dewey។ | • វឌ្ឍនភាពនៃការសាងសង់បណ្ណាល័យថ្មីនៅមានកម្រិត។<br>• ឆន្ទៈ និងការប្តេជ្ញាចិត្ត និងក្រមសីលធម៌ការងាររបស់បណ្ណារក្សមួយចំនួននៅមានកម្រិត។<br>• បណ្ណារក្សមិនទាន់មានគុណវុឌ្ឍិគ្រប់គ្រាន់។<br>• មានអ្នកចង់គិតគូរ ឬនិយាយអំពីបញ្ហាបណ្ណាល័យតិចតួចណាស់ ដែលជាឧត្តាពាំងដល់ការសម្រេចចក្ខុវិស័យរបស់បណ្ណាល័យ។ តាមរយៈការសម្ភាស មានអ្នកពាក់ព័ន្ធ២០%តែប៉ុណ្ណោះចង់គិត ឬនិយាយអំពីបញ្ហាបណ្ណាល័យ។<br>• គ្មានការពិនិត្យតាមដាន និងវាយតម្លៃលើការផ្តល់សេវាកម្មបណ្ណាល័យ។<br>• បណ្ណាល័យក្នុងគ្រឹះស្ថានឧត្តមសិក្សាផ្សេងទៀតមានកម្រិតខ្ពស់ឆ្ងាយបើធៀបនឹងស្តង់ដាបណ្ណាល័យសម្តេចព្រះសង្ឃរាជ ជួន ណាត។ វិសមភាពនេះអាចជះផលអវិជ្ជមានដល់កេរ្តិ៍ឈ្មោះ វជអ។ |

## ផែនការយុទ្ធសាស្ត្របណ្ណាល័យសម្តេចព្រះសង្ឃរាជ ជួន ណាត (២០២៤ - ២០២៨)

**ចក្ខុវិស័យ៖** បណ្ណាល័យសម្តេចព្រះសង្ឃរាជ **ជួន ណាត** មានចក្ខុវិស័យចង់ប្រែក្លាយខ្លួនជាបណ្ណាល័យឌីជីថលប្រកបដោយឧត្តមភាពឈានមុខគេនាសតវត្សទី២១ លើផ្នែកសិក្សាធិការសម្រាប់សហគមន៍នៃការអប់រំគ្រូបង្រៀន។

**បេសកកម្ម៖** បណ្ណាល័យសម្តេចព្រះសង្ឃរាជ ជួន ណាត មានបេសកកម្មផ្តល់ព័ត៌មាន និងផ្តល់សិទ្ធិអំណាចដល់អ្នកសិក្សា គ្រូបង្រៀន អ្នកដឹកនាំអប់រំ អ្នកស្រាវជ្រាវលើការបង្រៀននិងរៀន និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។

**គុណតម្លៃ៖** បណ្ណាល័យសម្តេចព្រះសង្ឃរាជ **ជួន ណាត** ផ្តល់គុណតម្លៃជាបេះដូងយុទ្ធសាស្ត្ររបស់វិទ្យាស្ថានជាតិអប់រំ។ បណ្ណាល័យសម្តេចព្រះសង្ឃរាជ **ជួន ណាត** ផ្សារភ្ជាប់គុណតម្លៃរបស់ខ្លួនទៅនឹងគុណតម្លៃរបស់វជអ។




**គុណភាព៖** សហគមន៍បណ្ណាល័យសម្ដេចព្រះសង្ឃរាជ **ជួន ណាត** ប្រឹងប្រែងផ្ដល់លទ្ធភាព និងសិទ្ធិទទួលបានធនធានអប់រំ និងសម្ភារៈសម្រាប់ការបណ្ដុះបណ្ដាលប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន ដើម្បីផ្ដល់ការគាំទ្រដល់ការផ្លាស់ប្ដូររបស់វជអទៅជាគ្រឹះស្ថានឧត្តមសិក្សាពេញលេញ។ គោលបំណងផ្ដល់ឱកាសសម្រាប់ការសិក្សាពេញមួយជីវិតដល់អ្នកសិក្សា តាមរយៈការពង្រឹងលើកម្មវិធីសិក្សា មុខវិជ្ជាសិក្សា និងការបណ្ដុះបណ្ដាល ដោយផ្ដល់នូវធនធានឌីជីថលទាន់សម័យស្របតាមស្ដង់ដាវិជ្ជាជីវៈ និងសមត្ថភាពរបស់គ្រូបង្រៀននាសតវត្សទី២១។ គ្រូបង្រៀនគ្រប់រូបអាចចូលរួមប្រើប្រាស់ធនធាននានារបស់បណ្ណាល័យនេះសម្រាប់ការជួយគាំទ្រដល់កម្មវិធីផ្សេងៗរបស់វិទ្យាស្ថានជាតិអប់រំ។

**សុចរិតភាព៖** សហគមន៍បណ្ណាល័យសម្ដេចព្រះសង្ឃរាជ **ជួន ណាត** ប្ដេជ្ញាគោរពគោលការណ៍តម្លាភាព គណនេយ្យភាព វិន័យ ភាពស្មោះត្រង់ និងមានស្ដង់ដាក្រមសីលធម៌វិជ្ជាជីវៈខ្ពស់។ បណ្ណារក្សទាំងអស់មានការប្ដេជ្ញាចិត្តក្នុងការតម្កល់កេរ្តិ៍ឈ្មោះ និងឧត្តមភាពល្បីល្បាញដែលឈានមុខគេនេះសម្រាប់ជាប្រយោជន៍រួមដល់អ្នកសិក្សា។

**ឧត្តមភាព៖** សហគមន៍បណ្ណាល័យសម្ដេចព្រះសង្ឃរាជ **ជួន ណាត** ប្ដេជ្ញាចិត្តរក្សាឧត្តមភាពលើគ្រប់សកម្មភាពនានា។ ពួកយើងខិតខំប្រឹងប្រែងផ្សារភ្ជាប់គុណតម្លៃស្នូលរបស់វជអ និងតួនាទីសំខាន់ៗចំនួនបីរួមមាន (១) ជាគ្រឹះស្ថានឧត្តមសិក្សាពេញលេញដែលផ្ដល់កម្មវិធីកម្រិតសញ្ញាបត្រ (២) ជាគ្រឹះស្ថានបណ្ដុះបណ្ដាលដំបូង និងការបណ្ដុះបណ្ដាលបន្តដល់គ្រូបង្រៀន និងមន្ត្រីគ្រប់គ្រងអប់រំគ្រប់កម្រិត (៣) ជាមជ្ឈមណ្ឌលស្រាវជ្រាវអប់រំមួយដែលផ្ដល់អនុសាសន៍ផ្អែកលើភស្តុតាងដើម្បីផ្សព្វផ្សាយគោលនយោបាយក្រសួងអប់រំ យុវជន និងកីឡា និងទិសដៅយុទ្ធសាស្ត្ររបស់វិទ្យាស្ថានជាតិអប់រំ។

**នវានុវត្តន៍៖** សហគមន៍បណ្ណាល័យសម្តេចព្រះសង្ឃរាជ **ជួន ណាត** ខិតខំផ្តល់ធនធានសិក្សាតាមរយៈថ្នាលឌីជីថល និងការប្រើប្រាស់បច្ចេកវិទ្យាសតវត្សទី២១ក្នុងនាមជាមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវការអប់រំប្រកបដោយនវានុវត្តន៍។

**សមធម៌៖** សហគមន៍បណ្ណាល័យសម្តេចព្រះសង្ឃរាជ **ជួន ណាត** របស់យើងប្តេជ្ញាចំពោះគោលការណ៍នៃភាពមិនលំអៀង ការគោរពចំពោះភាពចម្រុះ និងនិន្នាការផ្សេងៗ។ តម្លៃទាំងនេះនឹងជួយបណ្តុះវប្បធម៌នៃការផ្តល់ឱកាសសម្រាប់ឧត្តមភាពនៃការអប់រំសម្រាប់ទាំងអស់គ្នា ដោយមិនគិតថាអ្នកណាស្ថិតក្នុងកម្រិតណានោះឡើយ។

## ទិសយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្ររបស់បណ្ណាល័យសម្តេចព្រះសង្ឃរាជ **ជួន ណាត** ផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងគោលដៅយុទ្ធសាស្ត្ររបស់វជអ ដោយធានាថាបណ្ណាល័យនេះប្រែក្លាយខ្លួនឱ្យស្របទៅនឹងចក្ខុវិស័យរបស់វជអជាមជ្ឈមណ្ឌលនៃឧត្តមភាពពេញលេញ។ គោលដៅយុទ្ធសាស្ត្រនានានឹងផ្តល់ទិសដៅដល់ការអភិវឌ្ឍខ្លួន ទៅជាបណ្ណាល័យឌីជីថលប្រកបដោយឧត្តមភាពនាសតវត្សន៍ទី២១ ដែលឆ្លើយតបនឹងបរិបទជាតិ តំបន់ និងអន្តរជាតិ។ គោលដៅយុទ្ធសាស្ត្ររបស់បណ្ណាល័យនេះនឹងបង្កប់នូវក្តីសង្ឃឹមយ៉ាងមុតមាំ តាមរយៈការរួមបញ្ចូលនូវសកម្មភាពជាក់លាក់នានាក្នុងការធានាថា បណ្ណាល័យនេះអាចផ្តល់ភាពជាដៃគូប្រកបដោយនិរន្តរភាពជាមួយនឹងសកម្មភាពស្នូលរបស់វិទ្យាស្ថានជាតិអប់រំ។

អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (KAPE) បានអនុវត្តការស្រាវជ្រាវស្តីពីការវាយតម្លៃតម្រូវការ និងបានផលិតរបាយការណ៍អនុសាសន៍មួយសម្រាប់បណ្ណាល័យសម្តេចព្រះសង្ឃរាជ **ជួន ណាត** ស្របពេលកំពុងតែដំណើរការចងក្រងសៀវភៅផែនការយុទ្ធសាស្ត្របណ្ណាល័យ៥ឆ្នាំនេះ។ ឯកសារនេះបានផ្តោតសំខាន់លើការវិភាគតម្រូវការហេដ្ឋារចនាសម្ព័ន្ធរបស់បណ្ណាល័យ។

ការធានាគុណភាពនិងការកែលម្អ គឺជាសសរស្តម្ភគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រនេះប្រកបដោយប្រសិទ្ធភាព។ តាមរយៈរបាយការណ៍អនុសាសន៍របស់អង្គការខេបបានផ្តល់ការណែនាំថា "ការពិនិត្យឡើងវិញ" លើការអនុវត្តសកម្មភាពគោលដៅក្នុងផែនការយុទ្ធសាស្ត្រសម្តេចព្រះសង្ឃរាជ **ជួន ណាត** គួរតែអនុវត្តប្រចាំឆមាស ហើយ "ការពិនិត្យតាមដានស៊ីជម្រៅ" គួរតែធ្វើឡើងជាទៀងរាល់ពីរឆ្នាំម្តង។ វាគឺជាការពិនិត្យគុណភាពផ្ទៃក្នុង ដោយវាយតម្លៃលើគុណភាពបណ្ណាល័យជាមូលដ្ឋានសម្រាប់ការកែលម្អគុណភាពឱ្យសមស្របតាមវឌ្ឍនភាពនៃផែនការសកម្មភាពបណ្ណាល័យសម្តេចព្រះសង្ឃរាជ **ជួន ណាត** ក្នុងឯកសារនេះ។

បណ្ណារក្សនៃបណ្ណាល័យសម្តេចព្រះសង្ឃរាជ ជួន ណាត ត្រូវបំពេញការងារតាមគោលដៅយុទ្ធសាស្ត្រទាំងបីដោយត្រូវអនុវត្តគ្រប់សកម្មភាពតូចៗនានាក្នុងគោលដៅយុទ្ធសាស្ត្រ និងរបាយការណ៍អនុសាសន៍ ដើម្បីសម្រេចជោគជ័យ ក្នុងការអភិវឌ្ឍខ្លួនជាបណ្ណាល័យប្រកបដោយឧត្តមភាពឈានមុខគេនៅសតវត្សទី២១។ គោលដៅទាំងបីរបស់ផែនការយុទ្ធសាស្ត្រមានចំនួនប្រាំបួន ដែលមានទំនាក់ទំនងទៅនឹងយុទ្ធសាស្ត្រ និងគុណតម្លៃស្នូលរបស់វិទ្យាស្ថានជាតិអប់រំ ហើយសកម្មភាពគាំទ្រទាំងអស់ត្រូវបានបង្ហាញនៅក្នុងតារាងខាងក្រោម៖

| គោលដៅ | | |
|---|---|---|
| គោលដៅទី១<br>កម្មវិធីសិក្សា ការបង្រៀន និងការផ្សព្វផ្សាយ | គោលដៅទី២<br>ការពង្រឹងសមត្ថភាពបណ្ណាល័យ | គោលដៅទី ៣<br>ភាពជាដៃគូ និងបណ្ដាញ |

| **យុទ្ធសាស្ត្រ ១.១៖** | **យុទ្ធសាស្ត្រ ១.២៖** | **យុទ្ធសាស្ត្រ ២.១៖** | **យុទ្ធសាស្ត្រ ២.២៖** | **យុទ្ធសាស្ត្រ ២.៣៖** | **យុទ្ធសាស្ត្រ ២.៤៖** | **យុទ្ធសាស្ត្រ ២.៥៖** | **យុទ្ធសាស្ត្រ ៣.១៖** | **យុទ្ធសាស្ត្រ ៣.២៖** |
|---|---|---|---|---|---|---|---|---|
| កសាងឧត្តមភាព បណ្ណាល័យ ប្រកបដោយ នវានុវត្តន៍ ដើម្បីគាំទ្រ ដល់តម្រូវ ការសិក្សានៅ វជអ។ | អភិវឌ្ឍធនធាន មនុស្សដោយ ការគាំទ្រដល់ បណ្ណាល័យ។ | បណ្ដុះវប្បធម៌ នៃការជឿ ផ្សារភ្ជាប់ទៅ នឹងទុកចិត្ត សុខុមាល ភាព និងកិច្ច សហ ប្រតិបត្តិការ ដើម្បីគាំទ្រ ដល់ បេសកកម្ម របស់វជអ ។ | លើកកម្ពស់ ប្រសិទ្ធភាព នៃដំណើរ ការគាំទ្រ បណ្ណាល័យ។ | ពង្រឹងរចនា សម្ព័ន្ធ សម្រាប់គាំទ្រ ការប្រើប្រាស់ ធនធាន បណ្ណាល័យ | អភិវឌ្ឍ ហេដ្ឋារចនា សម្ព័ន្ធ បណ្ណាល័យ ដើម្បីគាំទ្រ ដល់ភាពជា អ្នកដឹកនាំ ការគ្រប់គ្រង ការរៀន ការ បង្រៀន និង ការស្រាវជ្រាវ ប្រកបដោយ ឧត្តមភាព របស់វជអ។ | បង្កើនបំណិន ស្រាវជ្រាវ ដល់ បណ្ណារក្ស | បង្កើនកេរ្តិ៍ ឈ្មោះ បណ្ណាល័យ ដោយផ្សារ ភ្ជាប់ទំនាក់ ទំនងជាមួយ នឹងកម្មវិធី សិក្សានៅ វជអ ការ សហការ ជាមួយគ្រូ ឧទ្ទេស បណ្ណារក្ស នៅកម្រិត មធ្យម សិក្សា។ | ពង្រឹងទំនាក់ ទំនងជាមួយ បណ្ណាល័យ កម្រិតជាតិ តំបន់ និង អន្តរជាតិ |

## គោលដៅទី ១៖ កម្មវិធី ការណែនាំ និងការផ្សព្វផ្សាយ

| គោលដៅ | យុទ្ធសាស្ត្រ |
|---|---|
| គោលដៅទី១៖ កម្មវិធីការណែនាំ និងការផ្សព្វផ្សាយ | **យុទ្ធសាស្ត្រ១.១៖ កសាងឧត្តមភាពបណ្ណាល័យប្រកបដោយនវានុវត្តន៍ ដើម្បីគាំទ្រដល់តម្រូវការសិក្សាក្នុងវជអ។**<br>1.1.1. ពិនិត្យលទ្ធភាព និងធនធានពាក់ព័ន្ធសម្រាប់ដំណើរការកម្មវិធីទាំងអស់នៅក្នុងសហគមន៍វជអ។<br>1.1.2. បង្កើនប្រសិទ្ធភាពការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធបណ្ណាល័យឌីជីថលប្រកបដោយភាពច្នៃប្រឌិត ដើម្បីគាំទ្រភាពជាអ្នកដឹកនាំអប់រំ ការបង្រៀន ការរៀន ការវាយតម្លៃ និងការស្រាវជ្រាវ។<br><br>**យុទ្ធសាស្ត្រ១.២៖ អភិវឌ្ឍធនធានមនុស្សដោយផ្សារភ្ជាប់ទៅនឹងការគាំទ្រដល់បណ្ណាល័យ។**<br>1.2.1. ជ្រើសរើសបណ្ណារក្សប្រកបដោយគុណវុឌ្ឍិជាបណ្ណារក្សសតវត្សទី២១ និងកំណត់តួនាទី ភារកិច្ចទទួលខុសត្រូវ។<br>1.2.2. លើកកម្ពស់ការរៀនពេញមួយជីវិត និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។ |

## គោលដៅទី២៖ ការពង្រឹងសមត្ថភាពបណ្ណាល័យ

| គោលដៅ | យុទ្ធសាស្ត្រ |
|---|---|
| គោលដៅទី២៖ ការពង្រឹងសមត្ថភាពបណ្ណាល័យ | **យុទ្ធសាស្ត្រ២.១៖ បណ្តុះវប្បធម៌នៃការជឿទុកចិត្ត សុខុមាលភាព និងកិច្ចសហប្រតិបត្តិការ ដើម្បីគាំទ្រដល់បេសកកម្មរបស់វេជអ**<br>2.1.1. ពង្រឹងទំនាក់ទំនងផ្ទៃក្នុង និងយន្តការផ្តល់មតិកែលម្អ។<br>2.1.2. បង្កើតឱកាសសម្រាប់ការចែករំលែកចំណេះដឹង និងទស្សនទាននានា។<br><br>**យុទ្ធសាស្ត្រ២.២៖ លើកកម្ពស់ប្រសិទ្ធភាពនៃដំណើរការគាំទ្របណ្ណាល័យ**<br>2.2.1 វិនិយោគលើដំណើរការគាំទ្របណ្ណាល័យ។<br>2.2.2 ពង្រឹងដំណើរការពិនិត្យតាមដាន និងការគាំទ្រ ដើម្បីវាស់វែងផលជះចេញពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់បណ្ណារក្ស។<br>2.2.3 បង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលលើដំណើរការជ្រើសរើសបណ្ណារក្ស និងការណែនាំ។<br><br>**យុទ្ធសាស្ត្រ២.៣៖ ពង្រឹងរចនាសម្ព័ន្ធសម្រាប់គាំទ្រការប្រើប្រាស់ធនធានបណ្ណាល័យ**<br>2.3.1. ពិនិត្យកែលម្អរចនាសម្ព័ន្ធ និងដំណើរការគាំទ្រផ្នែក ICT ។<br>2.3.2. ធានាប្រសិទ្ធភាពលើប្រតិបត្តិការរចនាសម្ព័ន្ធគាំទ្រដំណើរការរដ្ឋបាល ។<br><br>**យុទ្ធសាស្ត្រ២.៤៖ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបណ្ណាល័យ ដើម្បីគាំទ្រដល់ភាពជាអ្នកដឹកនាំ ការគ្រប់គ្រងការរៀន ការបង្រៀន និងការស្រាវជ្រាវប្រកបដោយឧត្តមភាពរបស់វេជអ**<br>2.4.1. អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបណ្ណាល័យ ដើម្បីគាំទ្រដល់ការបង្រៀន ការរៀនប្រកបដោយនវានុវត្តន៍សម្រាប់កម្មវិធីសិក្សាទាំងអស់ និងបង្កើនលទ្ធភាពដល់ការស្រាវជ្រាវ។<br>2.4.2. គាំទ្រវេជអតាមរយៈការបំពាក់គ្រឿងបរិក្ខារ ឬសម្ភារៈឧបទេសសម្រាប់ការសិក្សា និងការបណ្តុះបណ្តាលគរុកោសល្យ។<br><br>**យុទ្ធសាស្ត្រ២.៥៖ បង្កើនបំណិនស្រាវជ្រាវដល់បណ្ណារក្ស**<br>2.5.1. លើកកម្ពស់ចំណេះដឹង និងសមត្ថភាពបណ្ណារក្សលើបំណិនស្រាវជ្រាវ។<br>2.5.2. ពិនិត្យតាមដាននិន្នាការចុងក្រោយស្តីពីបណ្ណាល័យឌីជីថលសតវត្សទី២១។<br>2.5.3. ផ្តល់សេវាគាំទ្រលើការណែនាំ និងចំណេះដឹងស្តីពីការតែងនិពន្ធអត្ថបទស្រាវជ្រាវដល់វគ្គសិក្សានានានៅក្នុងកម្មវិធីសិក្សាទាំងអស់របស់វេជអ។<br>2.5.4. តាមដាននិន្នាការចុងក្រោយបំផុតនៃបណ្ណាល័យនៅកម្រិតមធ្យមសិក្សាចំណេះទូទៅ។ |

## គោលដៅទី៣ ៖ ភាពជាដៃគូ និងបណ្ដាញ

| គោលដៅ | យុទ្ធសាស្ត្រ |
|---|---|
| គោលដៅទី៣ ៖ ភាពជាដៃគូ និងបណ្ដាញ | **យុទ្ធសាស្ត្រ៣.១៖ បង្កើនកេរ្តិ៍ឈ្មោះបណ្ណាល័យដោយផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងកម្មវិធីសិក្សាក្នុងវជអ ការសហការជាមួយគ្រូឧទ្ទេស បណ្ណារក្សនៅកម្រិតមធ្យមសិក្សា។**<br>3.1.1. ផ្សារភ្ជាប់បណ្ណាល័យទៅនឹងកម្មវិធីសិក្សាទាំងអស់នៅវជអឱ្យកាន់តែមានភាពជិតស្និទ្ធ។<br>3.1.2. បង្កើតទំនាក់ទំនងជាមួយបណ្ណារក្សកម្រិតមធ្យមសិក្សាទុតិយភូមិដែលជាសាលារៀនគោលដៅ។<br>3.1.3. កសាងទំនាក់ទំនងជិតស្និទ្ធទៅនឹងគ្រូបង្រៀននៅវិទ្យាល័យគោលដៅ។<br>3.1.4. បង្កើតសហគមន៍បណ្ណាល័យសម្ដេចព្រះសង្ឃរាជ ជួន ណាត។<br>**យុទ្ធសាស្ត្រ៣.២៖ ពង្រឹងទំនាក់ទំនងជាមួយបណ្ណាល័យកម្រិតជាតិ តំបន់ និងអន្តរជាតិ**<br>3.2.1. អភិវឌ្ឍកិច្ចសហការ និងភាពជាដៃគូជាមួយនឹងបណ្ណាល័យជាតិ និងអន្តរជាតិដែលមានឧត្តមភាព។ |

## ក្របខណ្ឌពិនិត្យតាមដាន

សម្រាប់ផ្នែកយុទ្ធសាស្ត្រនីមួយៗ សកម្មភាពសំខាន់ៗក្នុងរយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ២០២៤ ដល់ឆ្នាំ ២០២៨ និងសូចនាករសំខាន់ៗនៃការអនុវត្តត្រូវបានគូសបញ្ជាក់ដូចខាងក្រោម៖

| គោលដៅទី១៖ កម្មវិធីសិក្សា ការបង្រៀន និងការផ្សព្វផ្សាយ | | | |
|---|---|---|---|
| **យុទ្ធសាស្ត្រ** | **សកម្មភាពគន្លឹះ** | **សូចនាករស្នូល** | **ទិសដៅ** |
| **យុទ្ធសាស្ត្រ១.១៖កសាងឧត្តមភាពបណ្ណាល័យប្រកបដោយនវានុវត្តន៍ដើម្បីគាំទ្រដល់តម្រូវការសិក្សាក្នុងវជអ** | | | |
| 1.1.1. ពិនិត្យលទ្ធភាព និងធនធានពាក់ព័ន្ធសម្រាប់ដំណើរការកម្មវិធីទាំងអស់នៅក្នុងសហគមន៍វជអ។ | 1.1.1.1. បង្កើតគោលការណ៍អភិវឌ្ឍឯកសារបណ្ណាល័យស្ដីពីសម្ភារៈសិក្សា គោលការណ៍ការបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវ និក្ខេបបទ ឯកសារអេឡិចត្រូនិច គោលការណ៍ប្រមូលសៀវភៅភាសាបរទេស និងធនធានឯកសារផ្សេងៗទៀតតាមរយៈការទិញ ឬការបរិច្ចាក គោលការណ៍ជម្រុះឯកសារ គោលការណ៍ខ្ចីសង និងការត្រួតពិនិត្យឡើងវិញ | • គោលការណ៍អភិវឌ្ឍឯកសារបណ្ណាល័យ<br>• គោលការណ៍ជម្រុះឯកសារ<br>• គោលការណ៍ខ្ចី-សង | • រៀបចំគោលការណ៍អភិវឌ្ឍឯកសារបណ្ណាល័យ |

| | | | |
|---|---|---|---|
| | លើគោលការណ៍ទាំងនេះជាប្រចាំ។ | | |
| | 1.1.1.2. បង្កើតសកម្មភាពលើឯកសារដែលមានស្រាប់។ | • កាលវិភាគ និងសកម្មភាព<br>• អត្រាភាគរយសៀវភៅបានធ្វើកាតាឡុក (របាយការណ៍ប្រចាំខែ ប្រចាំឆមាស ប្រចាំត្រីមាស និងប្រចាំឆ្នាំអំពីចំនួនសៀវភៅដែលបានធ្វើកាតាឡុករួច) | • កាលវិភាគយុទ្ធសាស្ត្រដែលបានកំណត់និងសកម្មភាពដែលបានបញ្ចប់ ១០០%។<br>• ១០០% នៃសៀវភៅទាំងអស់បានធ្វើកាតាឡុក និងធ្វើចំណាត់ថ្នាក់តាមប្រព័ន្ធកូដឌីវ៉េត្រឹមចុងឆ្នាំទី១។ |
| | 1.1.1.3. ពិនិត្យឡើងវិញលើតម្រូវការតាមមុខវិជ្ជា ដោយបន្សីគ្នាទៅនឹងឯកសារដែលមានស្រាប់គ្រប់ទម្រង់តាមកម្រិតសិក្សា។ | • ចំនួនឯកសារមុខវិជ្ជាឯកទេសបានពិនិត្យឡើងវិញ<br>• ចំនួននៃធនធានឌីជីថល<br>• ធនធានឯកសារដែលបានបាត់បង់ត្រូវបានកំណត់(បញ្ជីសារពើភ័ណ្ឌឯកសារបាត់) | • ១០០%នៃឯកសារមុខវិជ្ជាឯកទេសត្រូវបានពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្ម ឬមានផែនការដើម្បីធ្វើបច្ចុប្បន្នភាពបន្តជាប្រចាំ។<br>• កង្វះខាតលើធនធានឌីជីថលត្រូវបានកំណត់ |
| | 1.1.1.4. ជម្រះឯកសារដែលមិនពាក់ព័ន្ធទៅនឹងកម្មវិធីរបស់វជអ។ | • ឯកសារដែលមិនពាក់ព័ន្ធត្រូវបានដកចេញពីបណ្ណាល័យ(បញ្ជីសារពើភ័ណ្ឌឯកសារជម្រះ) | • បញ្ចប់ការត្រួតពិនិត្យ |
| | 1.1.1.5. សហការជាមួយមហាវិទ្យាល័យផ្សេងៗនៃវជអ ដើម្បីធ្វើបច្ចុប្បន្នកម្មលើបញ្ជីអំណាន។ | • បញ្ជីអំណានធ្វើបច្ចុប្បន្នភាព និងផ្ទុក VLE ក្នុងបណ្ណាល័យ។ | • ១០០%នៃបញ្ជីអំណានធ្វើបច្ចុប្បន្នកម្ម |

| | | | |
|---|---|---|---|
| | | | និងអាចចូលប្រើប្រាស់បាន |
| | 1.1.1.6. ស្ទង់មតិជាមួយសហគមន៍វេជអ ដើម្បីជានាបរិយាបន្ននៃការបណ្តុះបណ្តាល។ | • បង្កើតការស្ទង់មតិដោយប្រើប្រាស់កម្រងសំណួរពីស្ថានភាពមានពិការភាព Washington Group Question (WGQ)[1]។<br>• ភាគរយអ្នកសិក្សាមានចំណាប់អារម្មណ៍ថាទទួលបានការគាំទ្របន្ថែមកើនឡើង។ | • របាយការណ៍ដែលកំណត់ពីតម្រូវការសិក្សារបស់អ្នកសិក្សា។<br>• ១០០%នៃអ្នកសិក្សាទទួលអារម្មណ៍ថាបានការគាំទ្របន្ថែមនៅពេលប្រើប្រាស់បណ្ណាល័យ។ |
| | 1.1.1.7. រៀបចំទុកដាក់ឯកសារតាមលក្ខណៈបច្ចេកទេស។ | • មានផែនការក្នុងដៃ (ផែនការសកម្មភាពរៀបចំបណ្ណាល័យ) | • អ្នកសិក្សាទាំងអស់គ្នាអាចចូលទៅស្វែងរកធនធានឯកសារពីបណ្ណាល័យបាន |
| | 1.1.1.8. បង្កើតកម្មវិធីរកប្រាក់ចំណូលដើម្បីគាំទ្រដំណើរការបណ្ណាល័យ។ | • មានផែនការគ្រោងទុកដែលកំណត់នូវគំនិតផ្សេងៗសម្រាប់ការបង្កើតប្រាក់ចំណូល<br>• ចំនួនឯកសារក្នុងបណ្ណាល័យកើនឡើងដោយសារតែបណ្ណាល័យមានប្រាក់ចំណូល | • ៥% ភាគរយនៃថវិកាបណ្ណាល័យកើនឡើងតាមរយៈការរកចំណូលខាងក្រៅបាន។ |
| | 1.1.1.9. ប្រមូលឯកសារនានារួមទាំងគោលនយោបាយរដ្ឋាភិបាល ឯកសារស្រាវជ្រាវអប់រំ និងឯកសារការរៀន និងបង្រៀន។ល។ | • កំណត់លក្ខណៈ និងប្រភពនៃឯកសារនីមួយៗ ហើយបោះពុម្ព | • ឯកសារដែលបានកំណត់ត្រូវបានបោះពុម្ពនិងរក្សាទុកក្នុងបណ្ណាល័យ |
| | 1.1.1.10. ប្រែក្លាយឯកសាររឹងទៅជាឯកសារឌីជីថល(ប្តូរពីHard Copy ទៅជាSoft Copy)។ | • ផលិតឯកសារឌីជីថលបន្ថែមពីលើឯកសារដែលបានបោះពុម្ពទាំងអស់រួចរក្សាទុកក្នុងកន្លែងផ្ទុកទិន្នន័យ | • គ្រប់ឯកសារដែលបានបោះពុម្ពរួចនៅផ្នែក ១.១.១.៨ ត្រូវបានផលិតជា |

[1] កម្រងសំណួរស្ទង់មតិWGQ ជាប្រភេទការស្ទង់មតិស្តង់ដាអន្តរជាតិសម្រាប់វាយតម្លៃជនមានតម្រូវការពិសេស។

| | | | |
|---|---|---|---|
| | | ឱដីថលដែលអាចស្វែងរកបានក្នុងប្រទេសតែមួយគត់ (បញ្ជីសារពើភ័ណ្ឌឯកសារឱដីថល) | ឯកសារឱដីថល និងផ្តល់លទ្ធភាពដល់ការស្វែងរកតាមឱដីថលនៅគ្រប់ខេត្ត ឬតំបន់ទាំងអស់នៅកម្ពុជា |
| 1.1.2. បង្កើនប្រសិទ្ធភាពការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធបណ្ណាល័យឱដីថល ប្រកបដោយភាពច្នៃប្រឌិត ដើម្បីគាំទ្រភាពជាអ្នកដឹកនាំអប់រំ ការបង្រៀន ការរៀន ការវាយតម្លៃ និងការស្រាវជ្រាវ។ | 1.1.2.1. រៀបចំអាគារបណ្ណាល័យទាំងមូលទៅតាមលក្ខណៈបច្ចេកទេស។ | • ការសិក្សាវាយតម្លៃពីតម្រូវការ<br>• ប្លង់ទីតាំងរួមរបស់បណ្ណាល័យ ដែលបញ្ជាក់ពីមុខងារនៃការប្រើប្រាស់)<br><br>• ការស្ទង់មតិស្តីពីការពេញចិត្តរបស់បុគ្គលិក (ទិន្នន័យដើមគ្រា និងវឌ្ឍនភាព)<br><br>• លទ្ធផលនៃការស្ទង់មតិលើភាពពេញចិត្តរបស់គរុសិស្សទទួលការបណ្តុះបណ្តាលដំបូង(ទិន្នន័យដើមគ្រា និងវឌ្ឍនភាព)<br>• លទ្ធផលនៃការស្ទង់មតិលើភាពពេញចិត្តរបស់អ្នកសិក្សាទទួលការបណ្តុះបណ្តាលបន្ត (ទិន្នន័យដើមគ្រា និងវឌ្ឍនភាព)<br><br>• ទិន្នន័យវិភាគលើសកម្មភាព ឬចេញចូល ស្ថិតិអ្នកប្រើប្រាស់បណ្ណាល័យរបាយការណ៍) | • បំពេញការសិក្សាវាយតម្លៃពីតម្រូវការ (Needs assessment)<br><br>• X% ភាគរយនៃលទ្ធផលការពេញចិត្តរបស់បុគ្គលិកបង្ហាញការកើនឡើងក្នុងរយៈពេល៦ខែ។<br><br>• X% ភាគរយនៃលទ្ធផលការពេញចិត្តរបស់អ្នកសិក្សាទទួលការបណ្តុះបណ្តាលដំបូង និងការបណ្តុះបណ្តាលបន្ត បង្ហាញការកើនឡើងក្នុងរយៈពេល៦ខែ។<br><br>• X % ភាគរយនៃអ្នកសិក្សាអាចចូលទៅប្រើប្រាស់បណ្ណាល័យកើនឡើង ១៥%ពីមួយឆ្នាំទៅមួយឆ្នាំ។ |

| យុទ្ធសាស្ត្រ១.២៖ អភិវឌ្ឍធនធានមនុស្សដោយផ្សារភ្ជាប់ទៅនឹងការគាំទ្រដល់បណ្ណាល័យ | | | |
|---|---|---|---|
| 1.2.1. ជ្រើសរើសបណ្ណារក្សប្រកបដោយគុណវុឌ្ឍិជាបណ្ណារក្សសតវត្សទី២១ និងកំណត់តួនាទីភារកិច្ចទទួលខុសត្រូវ។ | 1.2.1.1. ធ្វើការជាមួយគណៈកម្មការបណ្ណាល័យដើម្បីធានាឧត្តមភាព និងស្តង់ដាបណ្ណាល័យសតវត្សទី២១។ | • កំណត់ហេតុការប្រជុំគណៈកម្មការបណ្ណាល័យដែលកំណត់មុខទំនិញ និងការត្រួតពិនិត្យឡើងវិញ | • របាយការណ៍ប្រចាំត្រីមាសគណៈកម្មការបណ្ណាល័យបង្ហាញពីការយកចិត្តទុកដាក់ដល់បណ្ណារក្សរួមទាំងផែនការអភិវឌ្ឍ |
| | 1.2.1.2. កំណត់តួនាទី និងទំនួលខុសត្រូវបណ្ណារក្ស។ | • តួនាទី ភារកិច្ច និងទំនួលខុសត្រូវ | • រៀបចំឯកសារដែលកំណត់ភារកិច្ច និងទំនួលខុសត្រូវសម្រាប់ការផ្សព្វផ្សាយធនធានបណ្ណាល័យជូនទៅកាន់ដេប៉ាតឺម៉ង់/មហាវិទ្យាល័យដទៃ។ |
| 1.2.2. លើកកម្ពស់ការរៀនពេញមួយជីវិត និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។ | 1.2.2.1. វាយតម្លៃការបំពេញការងារបណ្ណារក្ស។ | • ពិនិត្យឡើងវិញនូវគុណវុឌ្ឍិ និងឱកាសអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់បណ្ណារក្ស (ក្របខណ្ឌវាយតម្លៃគុណវុឌ្ឍិបណ្ណារក្ស) | • ការពិនិត្យឡើងវិញលើកម្រិតគុណវុឌ្ឍិ |
| | 1.2.2.2. ជ្រើសរើសបណ្ណារក្សសតវត្សទី២១តាមរយៈការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។ | • កត់ត្រាការបំពេញសវនកម្មលើជំនាញរបស់បណ្ណារក្ស | • បណ្ណារក្ស២រូបបញ្ចប់ការបណ្តុះបណ្តាលបរិញ្ញាបត្រជាន់ខ្ពស់ជំនាញគ្រប់គ្រងបណ្ណាល័យឆ្នាំ២០២៥ |
| | 1.2.2.3. បង្កើតផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំកម្រិតបុគ្គលដល់បណ្ណារក្សទាំងអស់គ្នា។ | • ផែនការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បណ្ណារក្ស | • បណ្ណាល័យបង្កើតផែនការអភិវឌ្ឍវិជ្ជាជីវៈប្រចាំឆ្នាំ |

| | | | |
|---|---|---|---|
| | 1.2.2.4. ពិនិត្យឡើងវិញលើតម្រូវការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមួយឆ្នាំម្តង។ | • រាល់បណ្ណារក្សទាំងអស់មានផែនការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | • ១០០%នៃបណ្ណារក្សទាំងអស់មានផែនការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដែលស្របតាមតម្រូវការអភិវឌ្ឍបុគ្គលម្នាក់ៗសម្រាប់អភិវឌ្ឍជាប្រចាំ |
| | 1.2.2.5. ផ្តល់កម្មវិធីតម្រង់ទិសស្តីពីការគ្រប់គ្រងបណ្ណាល័យ និងការបណ្តុះបណ្តាលបន្តដល់បណ្ណារក្ស | • កម្មវិធីតម្រង់ទិសស្តីពីបណ្ណាល័យ និងការបណ្តុះបណ្តាលបន្តត្រូវបានគ្រោងទុក<br>• បុគ្គលិកបណ្ណាល័យវេជអថ្មីចូលរួមក្នុងកម្មវិធីតម្រង់ទិសដែលបានគ្រោងទុក | • កម្មវិធីតម្រង់ទិស និងការបណ្តុះបណ្តាលបន្តត្រូវបានបង្កើតឡើង<br>• ១០០%នៃបុគ្គលិកថ្មីនៃបណ្ណាល័យវេជអចូលរួមក្នុងកម្មវិធីតម្រង់ទិស និងការបណ្តុះបណ្តាលបន្តដែលបានគ្រោងទុក |
| គោលដៅទី២៖ ការពង្រឹងសមត្ថភាពបណ្ណាល័យ | | | |
| **យុទ្ធសាស្ត្រ២.១៖ បណ្តុះវប្បធម៌នៃការជឿទុកចិត្ត សុខុមាលភាព និងកិច្ចសហប្រតិបត្តិការ ដើម្បីគាំទ្រដល់បេសកកម្មរបស់វេជអ** | | | |
| 2.1.1. ពង្រឹងទំនាក់ទំនងផ្ទៃក្នុង និងយន្តការផ្តល់មតិកែលម្អ។ | 2.1.1.1. បង្កើតគណៈកម្មការបណ្ណាល័យ | • រចនាសម្ព័ន្ធគណៈកម្មការបណ្ណាល័យ | • រចនាសម្ព័ន្ធគណៈកម្មការបណ្ណាល័យត្រូវបានបង្កើត និងចែករំលែកដល់អ្នកពាក់ព័ន្ធ |
| | 2.1.1.2. បង្កើតផែនការប្រតិបត្តិគ្រប់គ្រងសកម្មភាពប្រចាំឆ្នាំ។ | • ផែនការប្រតិបត្តិសម្រាប់បណ្ណាល័យ។ | • ផែនការប្រតិបត្តិប្រចាំឆ្នាំសម្រាប់បណ្ណាល័យបានបំពេញ |
| | 2.1.1.3. អនុវត្តក្របខណ្ឌពិនិត្យតាមដាន។ | • កំណាត់ហេតុរបស់គណៈកម្មការបណ្ណាល័យ | • កំណាត់ហេតុ និងសកម្មភាពរបស់គណៈកម្មការបណ្ណាល័យបង្ហាញវឌ្ឍន |

| | | | |
|---|---|---|---|
| | | • របាយការណ៍ត្រីមាស និងប្រចាំឆ្នាំផ្តល់ជូនដោយប្រធានបណ្ណាល័យ | ភាពជាភាគរយលើការបំពេញសកម្មភាព<br>• ផលិតរបាយការណ៍ដោយកំណត់នូវវឌ្ឍនភាព និងអ្វីៗដែលតម្រូវជាចាំបាច់សម្រាប់ការកែលម្អ។ |
| | 2.1.1.4. លើកកម្ពស់ និងគាំទ្រកិច្ចសហប្រតិបត្តិការរវាងមហាវិទ្យាល័យវេជអ និងបណ្ណាល័យ។ | • កំណត់ហេតុកិច្ចប្រជុំផ្ទៃក្នុងរបស់គណៈកម្មការបណ្ណាល័យ | • កំណត់ហេតុប្រជុំប្រចាំខែរបស់គណៈកម្មការបណ្ណាល័យបង្ហាញភាគរយនៃវឌ្ឍនភាពលើការបំពេញសកម្មភាព |
| | 2.1.1.5. រៀបចំកិច្ចសន្យាបំពេញការងាររបស់បណ្ណារក្ស។ | • ការពិនិត្យវាយតម្លៃបុគ្គលិក។<br>• របាយការណ៍វាយតម្លៃបុគ្គលិក។ | • ១០០%នៃបុគ្គលិកបំពេញការពិនិត្យវាយតម្លៃលើការបំពេញការងារ។<br>• ១០០%នៃបុគ្គលិកបានធ្វើផែនការ និងបំពេញ(ការវាយតម្លៃការបំពេញការងារដោយផ្ទៀងផ្ទាត់នឹងសូចនាករការបំពេញការងារក្នុងឆ្នាំនីមួយៗ) |
| | 2.1.1.6. រៀបចំគេហទំព័របណ្ណាល័យរួមទាំង VLE ។ | • ប្រតិបត្តការ VLE និងចំនួនអ្នកចូលបានកត់ត្រា | • ប្រតិបត្តការ VLE និងចំនួនអ្នកចូលបានកត់ត្រាដោយបែងចែកទៅតាមភេទ មុខវិជ្ជា ឬកម្មវិធី |

| | | | |
|---|---|---|---|
| | 2.1.1.7. ធ្វើស្វ័យវាយតម្លៃលើដំណើរការបណ្ណាល័យ។ | • បុគ្គលិកវេជអ និងសិស្សគួរត្រូវបានដឹងពីស្តង់ដាបណ្ណាល័យ | • បណ្ណារក្ស និងសិស្សត្រូវបានបែងចែកតាមការវិភាគរបស់ VLE និងស្តង់ដាបណ្ណាល័យ |
| 2.1.2. បង្កើតឱកាសសម្រាប់ការចែករំលែកចំណេះដឹង និងទស្សនទាននានា (ឧទាហរណ៍៖ សហគមន៍សិក្សាវិជ្ជាជីវៈ ក្លឹបអ្នកសិក្សា។ល។) | 2.1.2.1. អនុវត្តសកម្មភាពក្រៅម៉ោងសិក្សាទាក់ទងបណ្ណាល័យ (ឧ៖ ទិវាអំណាន ពិព័ណ៌បណ្ណាល័យជាដើម) | • មានផែនការរាល់សកម្មភាព | • មានផែនការរាល់សកម្មភាពសម្រាប់ឆ្នាំនីមួយៗ |
| **យុទ្ធសាស្ត្រ២.២៖ លើកកម្ពស់ប្រសិទ្ធភាពនៃដំណើរការគាំទ្របណ្ណាល័យ** | | | |
